# ព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម




ឆ្នាំទី៣២ លេខ៧៥៦ ខែកញ្ញា ឆ្នាំ២០២៥

# មាតិកា


## ០១ ស្ថិតិពាណិជ្ជកម្ម

១.១. សន្ទស្សន៍ថ្លៃទំនិញនៅលើទីផ្សាររាជធានីភ្នំពេញប្រចាំខែកញ្ញា ឆ្នាំ២០២៥ ...............០១
១.២. ការចុះបញ្ជីសហគ្រាសពាណិជ្ជកម្ម...........................................................០៣
១.៣. ការចុះបញ្ជីម៉ាកពាណិជ្ជនាម...................................................................០៥
១.៤. វិស័យនាំចេញរបស់កម្ពុជា.......................................................................០៧
១.៥. តម្លៃទំនិញប្រើប្រាស់ចាំបាច់សំខាន់ៗលើទីផ្សារអន្តរជាតិប្រចាំខែកញ្ញា ឆ្នាំ២០២៥......១១

## ០២ អត្ថបទស្រាវជ្រាវ

យុទ្ធសាស្ត្រពង្រីក និងពិពិធកម្មទីផ្សារនាំចេញអង្ករកម្ពុជាឆ្នាំ២០២៥-២០៣០..................១៦

## ០៣ ព័ត៌មានរបស់ក្រសួងពាណិជ្ជកម្ម

សកម្មភាពថ្នាក់ដឹកនាំ.................................................................................១៩

## ០៤ ព័ត៌មានទីផ្សារអន្តរជាតិ

ទីផ្សារនាំចេញទំនិញវៀតណាមមកកម្ពុជា ៧ខែដើមឆ្នាំ២០២៥៖................................២១

# ១-ស្ថិតិពាណិជ្ជកម្ម

## ◆ ១.១ សន្ទស្សន៍ថ្លៃទំនិញ នៅលើទីផ្សាររាជធានីភ្នំពេញ៖

តាមដានជាប្រចាំនូវថ្លៃទំនិញប្រើប្រាស់សំខាន់ៗ ដើម្បីកំណត់ពិដានថ្លៃលក់រាយនៅលើទីផ្សាររាជធានីភ្នំពេញ ប្រចាំខែកញ្ញា ឆ្នាំ២០២៥ ដូចជា៖(នៅលើទីផ្សារធំថ្មី, កណ្តាល, ច្បារអំពៅ, ដើមគរ, និងផ្សារអូរឫស្សី)។

- តារាងប្រៀបធៀបសន្ទស្សន៍តម្លៃទំនិញប្រចាំជីវភាពនៅលើទីផ្សារ

(ឯកតា៖ គិតជារៀល)

| ទំនិញ | ឯកតា | ខែសីហា ឆ្នាំ២០២៥ | ខែកញ្ញា ឆ្នាំ២០២៥ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|
| អង្ករផ្កាម្លិះ | គីឡូ/រៀល | 3,760 | 3,660 | -100 | ▼ 0.03 |
| អង្ករនាងម៉ិញ | គីឡូ/រៀល | 2,920 | 2,920 | - | - |
| សាច់គោ | គីឡូ/រៀល | 38,600 | 39,600 | 1,000 | ▲ 0.03 |
| សាច់ជ្រូក | គីឡូ/រៀល | 19,400 | 19,600 | 200 | ▲ 0.01 |
| សាច់មាន់ | គីឡូ/រៀល | 27,400 | 28,200 | 800 | ▲ 0.03 |
| ត្រីរស់ស្រស់ | គីឡូ/រៀល | 13,200 | 13,200 | - | - |

- តម្លៃអង្ករ៖ នៅក្នុងរាជធានីភ្នំពេញតម្លៃអង្ករលក់នៅលើទីផ្សារទាំង៥ សម្រាប់ខែកញ្ញា ឆ្នាំ២០២៥ បើធៀបទៅនឹងខែសីហា ឆ្នាំ២០២៥ នេះ ឃើញថាតម្លៃអង្ករផ្កាម្លិះមានតម្លៃថយ ១០០រៀល ស្មើនឹង(០,០៣%) និងអង្ករនាងម៉ិញមានតម្លៃថេរ ២៩២០រៀល។
- តម្លៃម្ហូបអាហារ៖ ក្នុងរាជធានីភ្នំពេញតម្លៃម្ហូបអាហារនៅលើទីផ្សារទាំង៥សម្រាប់ខែកញ្ញា ឆ្នាំ២០២៥ បើធៀបទៅនឹងខែសីហា ឆ្នាំ២០២៥ មានការប្រែប្រួលទៅលើមុខម្ហូបដូចជា៖ សាច់គោតម្លៃបានកើន ១០០០រៀល ស្មើនឹង(០,០៣%), សាច់ជ្រូកមានតម្លៃកើន ២០០រៀល ស្មើនឹង(០,០១), សាច់មាន់មានតម្លៃកើន ៨០០រៀល ស្មើនឹង(០,០៣%) និងត្រីរស់ស្រស់មានតម្លៃថេរ ១៣,២០០រៀល។
- រីឯទីផ្សារអន្តរជាតិវិញ ទីផ្សារអង្ករពិភពលោកនៅក្នុងខែកញ្ញា ឆ្នាំ២០២៥ តាមការសន្និដ្ឋានពីជំនាញការមួយចំនួន៖ តម្លៃអង្ករនៅលើទីផ្សារសង្ឃឹមថានឹងបានកើនឡើងវិញ ពីព្រោះប្រភពផ្គត់ផ្គង់ពីប្រទេសផលិតច្រើនដូចជា៖ ថៃ ឥណ្ឌា និងវៀតណាម មានការកើនឡើង។ តាមតួលេខពីក្រុមហ៊ុនស្បៀងអាហារឥណ្ឌា (FCI) បើគិតមកដល់ខែកញ្ញា ឆ្នាំ២០២៥នេះ ឃ្លាំងស្តុករបស់រដ្ឋាភិបាលបានកើនដល់ ៣៦,៩លានតោន ជាអង្ករសំរិត និង១៦,៩លានតោនជាស្រូវ ដែលជាតួលេខខ្ពស់ជាងច្រើនដងធៀបទៅនឹងកំរិតលំនឹង ១០,២៥លានតោន។

ប្រភព៖ Webside vinanet



- **តម្លៃប្រេងឥន្ធនៈ៖**
- តារាងប្រៀបធៀបសន្ទស្សន៍តម្លៃប្រេងឥន្ធនៈនៅលើទីផ្សារ

(ឯកតា៖ គិតជារៀល)

| **ទំនិញ** | **ឯកតា** | **ខែសីហា ឆ្នាំ២០២៥** | **ខែកញ្ញា ឆ្នាំ២០២៥** | **កើន(+) ថយ(-)** | **ភាគរយ (%)** |
|---|---|---|---|---|---|
| សាំងស៊ុបពែ | លីត្រ/រៀល | 4,400 | 4,450 | 50 | ▲ 0.01 |
| សាំងធម្មតា | លីត្រ/រៀល | 3,800 | 3,900 | 100 | ▲ 0.03 |
| ប្រេងម៉ាស៊ូត | លីត្រ/រៀល | 3,650 | 3,750 | 100 | ▲ 0.03 |
| ធ្យូង | រៀល/គី ក្រ | 2,000 | 2,000 | - | - |
| ហ្គាស | រៀល/15គី ក្រ | 68,000 | 68,500 | 500 | ▲ 0.01 |




**កំណើន**(+/-)%




- ប្រេងឥន្ធនៈ៖ តម្លៃប្រេងឥន្ធនៈនៅបណ្តាស្ថានីយ៍ក្រុមហ៊ុនទាំង០៩ របស់កម្ពុជាដូចជា ក្រុមហ៊ុនកម្ពុជាតេលាសូគីម៉ិច តូតាល់ ឈេហ្វរ៉ុន សាវីម៉ិច ប៊ីវីអឹម អិលអេចអរ ក្រុមហ៊ុនប៉ាប៉ា និងលឹម ឡុង ក្នុងបណ្តារាជធានីភ្នំពេញសម្រាប់ខែកញ្ញា ឆ្នាំ២០២៥ ធៀបទៅនឹងខែសីហា ឆ្នាំ២០២៥ ក្នុងនោះតម្លៃសាំងស៊ុបពែមានតម្លៃកើន ៥០រៀល ស្មើនឹង(០,០១%), សាំងធម្មតាមានតម្លៃកើន ១០០រៀល ស្មើនឹង(០,០៣), ប្រេងម៉ាស៊ូតមានតម្លៃកើន ១៩០ រៀល ស្មើនឹង(០,០៣) តម្លៃធ្យូងមានការថេរ ២០០០រៀល និងតម្លៃហ្គាសមានការកើន ៥០០រៀល ស្មើ(០,០១)។
- រីឯទីផ្សារអន្តរជាតិវិញនៅក្នុងខែកក្កដា ឆ្នាំ២០២៥ តម្លៃប្រេងឆៅពិភពលោកបានថយចុះ ខណៈដែលប្រភពផ្គត់ផ្គង់កើនឡើងខ្ពស់-តម្រូវការថយចុះនៅអាម៉េរិក នឹងស្ថានភាពនយោបាយឡើងកំដៅខ្លាំងនៅតំបន់មជ្ឈឹមបូព៌ា និងអឺរ៉ុបខាងកើត។

ប្រភព៖ Website Vinanet

## ១.២ ការចុះបញ្ជីសហគ្រាសពាណិជ្ជកម្ម

- តារាងប្រៀបធៀបចំនួនក្រុមហ៊ុន ដែលបានចុះបញ្ជីពាណិជ្ជកម្មក្នុងខែកញ្ញា ឆ្នាំ២០២៥ (ឯកតា៖ ចំនួនក្រុមហ៊ុន)

| ប្រភេទក្រុមហ៊ុន | ខែសីហា ឆ្នាំ២០២៥ | ខែកញ្ញា ឆ្នាំ២០២៥ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|
| **ករណីស្នើសុំចុះបញ្ជីពាណិជ្ជកម្ម(ថ្មី)** | | | | |
| ក្រុមហ៊ុនមូលធន | 651 | 620 | -30 | ▼ 0.05 |
| ក្រុមហ៊ុនពាណិជ្ជកម្មបរទេស | 6 | 7 | 1 | ▲ 0.17 |
| សហគ្រាសឯកបុគ្គល | 464 | 528 | 64 | ▲ 0.14 |
| **ករណីស្នើសុំលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម** | | | | |
| ក្រុមហ៊ុនមូលធន | 105 | 136 | 31 | ▲ 0.30 |
| ក្រុមហ៊ុនពាណិជ្ជកម្មបរទេស | 3 | 3 | - | - |
| សហគ្រាសឯកបុគ្គល | 26 | 25 | -1 | ▼ 0.04 |
| **ករណីស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណតាមប្រព័ន្ធអេឡិចត្រូនិក** | | | | |
| លិខិតអនុញ្ញាតសម្រាប់រូបវន្តបុគ្គល | 7 | 2 | -5 | ▼ 0.71 |
| លិខិតអនុញ្ញាតសហគ្រាសឯកបុគ្គល | - | - | - | - |
| អាជ្ញាបណ្ណ | 5 | 5 | - | - |
| **ករណីស្នើសុំចុះបញ្ជីកែប្រែ** | | | | |
| ការកែប្រែផ្លាស់ប្តូរភាគហ៊ុន | 141 | 141 | - | - |
| ការបន្ថយដើមទុន | 6 | 1 | -5 | ▼ 0.83 |
| ការបង្កើនដើមទុន | 66 | 62 | -4 | ▼ 0.06 |
| ការកែប្រែផ្សេងៗ (អភិបាល កម្មវត្ថុ.........) | 1120 | 975 | -145 | ▼ 0.13 |
| ការបង្កើតសាខាក្រុមហ៊ុនក្នុងស្រុក | 48 | 59 | 11 | ▲ 0.23 |
| ការកែប្រែសហគ្រាសឯកបុគ្គល | 68 | 62 | -6 | ▼ 0.09 |

## ក្រាហ្វិកករណីស្នើសុំចុះបញ្ជីពាណិជ្ជកម្ម (ថ្មី)




## ក្រាហ្វិកករណីស្នើសុំលុបឈ្មោះ




## ក្រាហ្វិកករណីស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណតាមប្រព័ន្ធអេឡិចត្រូនិក




## ក្រាហ្វិកស្នើសុំចុះបញ្ជីកែប្រែ



## ១.៣ ការចុះបញ្ជីម៉ាកពាណិជ្ជនាមៈ

- តារាងប្រៀបធៀបចំនួនម៉ាកពាណិជ្ជនាមដែលបានចុះបញ្ជីនៅក្នុងខែកញ្ញា ឆ្នាំ២០២៥

(ឯកតា៖ គិតជាចំនួនម៉ាក)

| ការផ្តល់សេវាផ្សេងៗ ពាក់ព័ន្ធ និងកិច្ចការពារម៉ាក | ខែសីហា ឆ្នាំ២០២៥ | ខែកញ្ញា ឆ្នាំ២០២៥ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|
| **ការចុះបញ្ជីម៉ាក** (Registration) | | | | |
| ម៉ាកក្នុងស្រុក | 216 | 135 | -81 | ▼ 0.38 |
| ម៉ាកក្រៅស្រុក | 161 | 182 | 21 | ▲ 0.13 |
| តាមប្រព័ន្ធម៉ាឌ្រីដ | 171 | 116 | -55 | ▼ 0.32 |
| **ការទទួលពាក្យស្នើសុំចុះបញ្ជីម៉ាក** | | | | |
| បញ្ជាក់អំពីការប្រើប្រាស់ឬមិនប្រើប្រាស់ម៉ាក | 225 | 346 | 121 | ▲ 0.54 |
| ការបញ្ជាក់អំពីការប្រើប្រាស់ ឬមិនប្រើប្រាស់ម៉ាកតាមប្រព័ន្ធម៉ាឌ្រីដ | 86 | 222 | 136 | ▲ 1.58 |
| ការចុះបញ្ជីម៉ាកសារជាថ្មី | 199 | 266 | 67 | ▲ 0.34 |
| ការចុះបញ្ជីម៉ាកសារជាថ្មីតាមប្រព័ន្ធម៉ាឌ្រីដ | 23 | 77 | 54 | ▲ 2.35 |
| ការកត់ត្រាសិទ្ធិផ្តាច់មុខ | 7 | 7 | - | - |
| ការកត់ត្រាផ្ទេរម្ចាស់កម្មសិទ្ធិម៉ាកដែលបានចុះបញ្ជី | 68 | 24 | -44 | ▼ 0.65 |
| ការធ្វើទុតិយតាវិញ្ញាបនបត្រចុះបញ្ជីម៉ាក | 12 | 3 | -9 | ▼ 0.75 |
| ការផ្លាស់ប្តូរផ្សេងៗ | 137 | 120 | -17 | ▼ 0.12 |

សម្គាល់៖ ការចុះបញ្ជីម៉ាក មានរយៈពេលពី៥-៧ខែ យោងតាមប្រកាសអន្តរក្រសួងលេខ ៣១៥ សហវ.ប្រក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១។

- ចំពោះការចុះបញ្ជីម៉ាកតាមប្រព័ន្ធម៉ាឌ្រីដ កម្ពុជាជ្រើសរើសយករយៈពេល១៨ខែ យោងតាមពិធីសារទីក្រុងម៉ាឌ្រីដ ដែលកម្ពុជាចូលជាសមាជិក និងចូលជាធរមាននៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៥។
- ចំពោះការបដិសេធការស្នើចុះបញ្ជីម៉ាកខាងលើ នាយកដ្ឋានបានចេញលិខិតទៅអ្នកដាក់ពាក្យស្នើសុំដើម្បីធ្វើការឆ្លើយតប។

**ក្រាហ្វិកការចុះបញ្ជីម៉ាកពាណិជ្ជនាម** ( Registration )




**ការទទួលពាក្យស្នើសុំចុះបញ្ជីម៉ាក**



## ១.៤ វិស័យនាំចេញរបស់កម្ពុជា

- **ការនាំចេញផលិតផលពីកម្ពុជា ទៅបណ្តាប្រទេសក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី**( Cambodian Export Under FTA GSP and MFN Scheme )

តារាងប្រៀបធៀបតម្លៃផលិតផលនាំចេញពីកម្ពុជាទៅបណ្តាប្រទេស ក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី

( ឯកតា ៖ ដុល្លារអាម៉េរិក )

| ប្រភេទទំនិញ | ខ្នាត | ខែសីហា ឆ្នាំ២០២៥ | ខែកញ្ញា ឆ្នាំ២០២៥ | កើន( + ) ថយ( - ) | ភាគរយ ( % ) |
|---|---|---|---|---|---|
| សំលៀកបំពាក់ | DOZ | 882,408,765 | 689,215,067 | -193,193,698 | ▼ 0.22 |
| វាយនភ័ណ្ឌ | N/A | 7,889,736 | 11,477,979 | 3,588,243 | ▲ 0.45 |
| ស្បែកជើង | PRS | 150,084,229 | 153,280,881 | 3,196,652 | ▲ 0.02 |
| កាបូបធ្វើដំណើរ | DOZ | 212,883,527 | 190,437,449 | -22,446,078 | ▼ 0.11 |
| កង់ | SET | 46,403,213 | 41,354,080 | -5,049,133 | ▼ 0.11 |
| អង្ករ | N/A | 259,387,458 | 185,905,958 | -73,481,500 | ▼ 0.28 |
| ទំនិញកសិកម្ម | - | 214,080,203 | 145,380,127 | -68,700,076 | ▼ 0.32 |
| ផលិតផលផ្សេងៗ | N/A | 785,287,482 | 955,673,606 | 170,386,124 | ▲ 0.22 |
| **សរុបរួម** | | **2,558,424,612** | **2,572,725,148** | **14,300,536** | ▲ **0.01** |

- ប្រភពនាយកដ្ឋាននាំចេញ នាំចូល៖ តួលេខនាំចេញនេះ ជាតួលេខដែលទទួលបានក្រោមការផ្តល់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ។

## ក្រាហ្វិកតម្លៃផលិតផលនាំចេញពីកម្ពុជាទៅបណ្តាប្រទេស ក្រោមប្រព័ន្ធ អនុគ្រោះពាណិជ្ជកម្ម និងពាណិជ្ជកម្មសេរី លើទីផ្សារពិភពលោក






- **ប្រទេសនាំចេញទំនិញពីកម្ពុជា ក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី** ( Cambodian Export Under FTA GSP and MFN Scheme )

តារាងប្រៀបធៀបប្រទេសនាំចេញតម្លៃទំនិញពីកម្ពុជាទៅបណ្តាប្រទេស ក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម នឹងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី

( ឯកតា៖ ដុល្លារអាម៉េរិក )

| ប្រទេស | ខែសីហា ២០២៥ | ខែកញ្ញា ២០២៥ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|
| អាម៉េរិក | 1,102,981,147 | 1,158,535,855 | 55,554,708 | ▲ 0.05 |
| អង់គ្លេស | 91,563,900 | 89,372,298 | -2,191,602 | ▼ 0.02 |
| សហគមន៍អឺរ៉ុប | 288,415,770 | 335,005,838 | 46,590,068 | ▲ 0.16 |
| កាណាដា | 142,180,897 | 107,743,644 | -34,437,253 | ▼ 0.24 |
| អាស៊ាន | 503,984,145 | 425,036,561 | -78,947,584 | ▼ 0.16 |
| ជប៉ុន | 144,163,309 | 141,136,330 | -3,026,979 | ▼ 0.02 |
| ចិន | 137,857,776 | 177,348,628 | 39,490,852 | ▲ 0.29 |
| អូស្ត្រាលី | 15,033,697 | 16,739,165 | 1,705,468 | ▲ 0.11 |
| ឥណ្ឌា | 14,921,318 | 10,354,800 | -4,566,518 | ▼ 0.31 |
| ណូវ៉ែលហ្សេឡង់ | 1,303,542 | 1,621,807 | 318,265 | ▲ 0.24 |
| អារ៉ាប៊ីសាអូឌីត | 4,696,189 | 4,939,831 | 243,642 | ▲ 0.05 |
| កូរ៉េ | 27,185,658 | 22,515,791 | -4,669,867 | ▼ 0.17 |
| បណ្តាប្រទេសផ្សេងៗក្នុងពិភពលោក | 84,137,264 | 82,374,600 | -1,762,664 | ▼ 0.02 |
| **សរុបរួម** | **2,558,424,612** | **2,572,725,148** | **14,300,536** | ▲ **0.01** |

- ប្រភពនាយកដ្ឋាននាំចេញ នាំចូល៖ តួលេខនាំចេញនេះ ជាតួលេខដែលទទួលបាន ក្រោមការផ្តល់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ។

## ក្រាហ្វិកការនាំចេញរបស់កម្ពុជា






## ១.៥ តម្លៃទំនិញប្រើប្រាស់ចាំបាច់សំខាន់ៗ លើទីផ្សារអន្តរជាតិប្រចាំខែកញ្ញា ឆ្នាំ២០២៥

- **អង្ករ៖**

(ឯកតា៖ ដុល្លារអាមេរិក/តោន)

| មុខទំនិញ | លក្ខខណ្ឌ ប្រគល់-ទទួល | ខែសីហា ឆ្នាំ២០២៥ | ខែកញ្ញា ឆ្នាំ២០២៥ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|
| អង្ករប្រភេទបាក់5% | FOB Bangkok | 379 | 352 | -5 | ▼ 1.40 |
| អង្ករប្រភេទបាក់5% | FOB Vietnam | 383 | 379 | -2 | ▼ 0.52 |
| អង្ករប្រភេទបាក់5% | FOB India | 381 | 376 | -3 | ▼ 0.79 |
| អង្ករប្រភេទបាក់5% | FOB មីយ៉ាន់ម៉ា | 369 | 327 | -28 | ▼ 7.89 |
| អង្ករប្រភេទបាក់5% | FOB USA | 654 | 606 | 6 | ▲ 1.00 |
| អង្ករប្រភេទបាក់5% | FOB ប៉ាគីស្ថាន | 380 | 355 | -2 | ▼ 0.56 |
| អង្ករប្រភេទបាក់25% | FOB Bangkok | 362 | 336 | -2 | ▼ 0.59 |
| អង្ករប្រភេទបាក់25% | FOB Vietnam | 360 | 357 | -1 | ▼ 0.28 |
| អង្ករប្រភេទបាក់25% | FOB India | 360 | 362 | -1 | ▼ 0.28 |
| អង្ករក្រហមប្រភេទ (Hommali) 100% | FOB Bangkok | 384 | 365 | -3 | ▼ 0.82 |
| អង្ករក្រហមប្រភេទ5% | FOB India | 374 | 376 | -3 | ▼ 0.79 |
| អង្ករប្រភេទហូមមាលី (hommali)100% | FOB Bangkok | 1030 | 1118 | 47 | ▲ 4.39 |
| អង្ករក្រអូប | FOB Vietnam | 559 | 499 | -52 | ▼ 9.44 |

- កត់សំគាល់៖ តម្លៃអង្ករលក់ចេញនៅទីផ្សារសំខាន់ៗនៅក្នុងខែកញ្ញា ឆ្នាំ២០២៥ នេះ គឺមានការប្រែប្រួលធៀបទៅនឹងខែសីហា ឆ្នាំ២០២៥។
- ក្នុងខែកញ្ញា ឆ្នាំ២០២៥នេះ នៅប្រទេសថៃ តម្លៃអង្ករនាំចេញគ្រប់ប្រភេទលើកលែងប្រភេទក្រអូបប្រភេទបាក់បានថយចុះពី ២ទៅ៥ ដុល្លារ/តោន(FOB, Bangkok) ធៀបទៅនឹងខែបន្ទាប់ ដោយអង្ករប្រភេទ ៥% លក់ចេញក្នុងតម្លៃ ៣៥២ ដុល្លារ/តោន(FOB, Bangkok) និងប្រភេទ ២៥% លក់ចេញក្នុងតម្លៃ ៣៣៦ដុល្លារ/តោន (FOB, Bangkok) និងផ្ទុយទៅវិញប្រភេទហូមមាលីបានកើនឡើង ៤៧ដុល្លារ/តោន លក់ចេញក្នុងតម្លៃ១១១៨ដុល្លារ/តោន (FOB, Bangkok) និងនៅវៀតណាម តម្លៃអង្ករនាំចេញបានថយចុះពី១ទៅ៥២ដុល្លារ/តោន ធៀបខែបន្ទាប់ដោយអង្ករប្រភេទ ៥% លក់ចេញក្នុងតម្លៃ ៣៧៩ដុល្លារ/តោន(FOB, Vietnam) និងប្រភេទ ២៥% លក់ចេញក្នុងតម្លៃជាមធ្យម ៣៥៧ដុល្លារ/តោន(FOB, កំពង់ផែក្រុងហូជីមិញ)។ និងអង្ករប្រភេទក្រអូបប្រភេទបាក់លក់ចេញក្នុងតម្លៃមធ្យម ៤៩៩ដុល្លារ/តោន(FOB,កំពង់ផែ

ក្រុងហូជីមិញ)។

- តម្លៃអង្ករនាំចេញនៅលើទីផ្សារអាស៊ី គឺបានថយចុះក្នុងតម្លៃមួយទាបបំផុតក្នុងរយៈពេល៨ឆ្នាំកន្លងមកដោយសាររដូវច្រូតកាត់មានអំណោយផលល្អ ជាពិសេសនៅឥណ្ឌា ប្រទេសផលិតអង្ករច្រើនបំផុតលើពិភពលោក។ បើតាមសមាគមអង្គការស្បៀងអាហារពិភពលោក(FAO)បានឲ្យដឹងថា៖បរិមាណផលិតផលអង្ករពិភពលោកនៅរដូវឆ្នាំ២០២៥-២៦នឹងទទួលបានក្នុងកំរិតខ្ពស់បំផុត ៥៥៦,៤លានតោន។ នៅប្រទេសហ្វីលីពីន បើគិតមកដល់ចុងខែកញ្ញា ឆ្នាំ២០២៥ នេះ គឺបាននាំចូលអង្ករចំនួន ៨០០០០០តោន និងតាមសេចក្តីប្រកាសថ្មីបំផុតរបស់នាយកដ្ឋានកសិកម្មអាម៉េរិក (USDA) នៅក្នុងឆ្នាំ២០២៥-២៦ ហ្វីលីពីននឹងធ្វើការនាំចូលអង្ករចំនួនដល់ទៅ៥លានតោន ច្រើនជាងប្រទេសចិន និងទៅជាប្រទេសនាំចូលអង្ករច្រើនបំផុតលើពិភពលោក។ តាមសារព័ត៌មាន Bloomberg, ហ្វីលីពីននឹងធ្វើការផ្អាកនាំចូលអង្កររហូតដល់ខែមេសាឆ្នាំ២០២៦ដើម្បីរក្សាតម្លៃអង្ករក្នុងស្រុកខណៈដែលរដូវច្រូតកាត់ស្រូវរដូវវស្សាបានមកដល់ជាមូលហេតុជះឥទ្ធិពលទីផ្សារអង្ករពិភពលោក។ នៅប្រទេសបង់ក្លាដេសតម្លៃអង្ករក្នុងស្រុកខ្ពស់ជាងពី១០ ទៅ២០% ធៀបឆ្នាំមុន ដោយសារតម្រូវការកើនឡើង និងប្រទេសកូរ៉េបរិមាណផលិតផលនៅក្នុងឆ្នាំ២០២៥ នឹងទទួលបានចំនួន៣,៥៧លានតោន គឺបានថយចុះរយៈពេល ៤ឆ្នាំបន្តបន្ទាប់ ដោយសារផ្ទៃដីដាំដុះថយចុះ។ តាមការសន្និដ្ឋានពីជំនាញការមួយចំនួន៖ តម្លៃអង្ករនៅលើទីផ្សារសង្ឃឹមថានឹងបានកើនឡើងវិញ ពីព្រោះប្រភពផ្គត់ផ្គង់ពីប្រទេសផលិតច្រើនដូចជា៖ ថៃ ឥណ្ឌា និងវៀត-ណាម មានការកើនឡើង។ តាមតួលេខពីក្រុមហ៊ុនស្បៀងអាហារឥណ្ឌា (FCI) បើគិតមកដល់ខែកញ្ញា ឆ្នាំ២០២៥នេះ ឃ្លាំងស្តុករបស់រដ្ឋាភិបាលបានកើនដល់ ៣៦,៩លានតោនជាអង្ករសំរិត និង១៦,៩លានតោនជាស្រូវ ដែលជាតួលេខខ្ពស់ជាងច្រើនដងធៀបទៅនឹងកំរិតលំនឹង ១០,២៥លានតោន។ រីឯបរិមាណអង្ករនាំចេញនៅឆ្នាំ២០២៥-២៦ អាចនឹងកើនដល់ ២៥លានតោន កើន ១លានតោន ធៀបទៅនឹងរដូវកាលឆ្នាំមុន។ មួយក្នុងចំណោមព័ត៌មានសំខាន់ពីឥណ្ឌាកំពុងជះឥទ្ធិពលដល់ទីផ្សារផលិតផលបន្ទាប់បន្សំពីអង្ករ គឺនៅថ្ងៃទី០៣ ខែតុលានេះ រដ្ឋាភិបាល បានប្រកាសលុបច្បាប់ហាមនាំចេញកន្ទក់ ដែលជាច្បាប់មួយមានប្រសិទ្ធភាពរយៈពេល២ឆ្នាំកន្លងមកហើយ។ មុននឹងច្បាប់ត្រូវបានអនុវត្តនៅក្នុងខែកក្កដា ឆ្នាំ២០២៣ ឥណ្ឌាបាននាំចេញកន្ទក់ចំនួន ៥០០០០០តោន/ឆ្នាំស្មើនឹង ១០ពាន់លានrupee ទៅកាន់ទីផ្សារសំខាន់ដូចជា៖ វៀតណាម ថៃ និងទីផ្សារអាស៊ីផ្សេងទៀត។ ការបើកឲ្យមានការនាំចេញឡើងវិញនូវផលិតផលបន្ទាប់បន្សំពីស្រូវ-អង្ករ បានរួមចំណែកក្នុងការរក្សាតម្លៃជាពិសេសតម្លៃអង្ករសំរិត រួមចំណែកស្តារឡើងវិញទីផ្សារអង្ករពិភពលោក។

- **កសិផល៖**

(ឯកតា៖ដុល្លារអាម៉េរិក/តោន)

| **មុខទំនិញ** | **លក្ខខណ្ឌ ប្រគល់-ទទួល** | **ខែសីហា ឆ្នាំ២០២៥** | **ខែកញ្ញា ឆ្នាំ២០២៥** | **កើន(+) ថយ(-)** | **ភាគរយ (%)** |
|---|---|---|---|---|---|
| ស្រូវសាលី | FOB USA | 193.50 | 186.09 | -4.91 | ▼ 2.57 |
| ពោត | - | 145.00 | 152.15 | -1.99 | ▼ 1.29 |
| សណ្តែកសៀង | - | 354.23 | 366.00 | -13 | ▼ 3.43 |
| ប្រេងដូងមិនទាន់កែច្នៃ | FOB, Malaysia | 1008.72 | 1033.75 | -20.45 | ▼ 1.94 |
| ប្រេងសណ្តែកសៀង | CIF Rotterdam | 1050.00 | 1105.50 | -34.9 | ▼ 3.06 |
| គ្រាប់ម្រេចខ្មៅ | FOB (V.N) | 5,305.50 | 5,660.00 | 109.5 | ▲ 1.97 |

| | | | | | |
|---|---|---|---|---|---|
| គ្រាប់ម្រេចស | FOB (V.N) | 6,910.50 | 7,180.00 | 130 | ▲ 1.84 |
| កាហ្វេ(ROBUSTA) | FOB New York(USA) | 3,331.00 | 4,186.00 | -123 | ▼ 2.85 |
| កាហ្វេ(ARABICA) | London | 6,513.50 | 7,904.10 | -566.9 | ▼ 6.69 |
| កប្បាសលេខ២ | FOB New York | 1,438.87 | 1,394.50 | -63.2 | ▼ 4.34 |
| កាកាវ(ដុល្លារ/តោន) | CIF New York (USA) | 8,459.00 | 6,707.00 | -692 | ▼ 9.35 |

- កត់សំគាល់៖ តម្លៃកសិផលគ្រប់ប្រភេទមានការប្រែប្រួលទៅតាមប្រភេទនីមួយៗ នៅខែកញ្ញា ឆ្នាំ២០២៥ នេះ។
- តម្លៃពោត៖ នៅក្នុងខែកញ្ញា ឆ្នាំ២០២៥ នេះ តម្លៃពោតនាំចេញនៅ Chicago បានថយចុះជាមធ្យម ១,៩៩ដុល្លារ/តោន (១,២៩%) ធៀបខែសីហា ដោយលក់ចេញក្នុងតម្លៃ ១៥២,១៥ដុល្លារ/តោន (FOB, Chicago)។
- តម្លៃស្រូវសាលី៖ តម្លៃស្រូវសាលីនាំចេញទៅ Chicago បានថយចុះជាមធ្យម ៤,៩១ដុល្លារ/តោន (២,៥៧%)ធៀបខែកញ្ញា ឆ្នាំ២០២៥ ដោយលក់ចេញក្នុងតម្លៃជាមធ្យម ១៨៦,០៩ដុល្លារ/តោន (FOB, Chicago)។
- តម្លៃសណ្តែកសៀង៖ នៅ Chicago តម្លៃសណ្តែកសៀងនាំចេញបានលក់ចេញតម្លៃបានថយចុះជាមធ្យម ១៣,០០ ដុល្លារ/តោន (៣,៤៣%) ដោយលក់ចេញក្នុងតម្លៃមធ្យម ៣៦៦,០០ដុល្លារ/តោន, FOB, Chicago។
- តម្លៃប្រេងដូងប្រេង៖ តម្លៃប្រេងដូងប្រេងនៅទីផ្សារប្រទេសម៉ាឡេស៊ីនៅក្នុងខែតុលា ឆ្នាំ២០២៥ បានថយចុះជាមធ្យម ២០,៤៥ដុល្លារ/តោន (១,៩៤%) ដោយលក់ចេញក្នុងតម្លៃមធ្យម ១០៣៣,៧៥ដុល្លារ/តោន (FOB, Malaysia )។
- តម្លៃកាហ្វេ៖ នៅខែតុលា ឆ្នាំ២០២៥ នេះតម្លៃកាហ្វេនាំចេញគ្រប់ប្រភេទបានថយចុះ ធៀបទៅនឹងខែបន្ទាប់។ នៅទីផ្សារ New York តម្លៃកាហ្វេរ៉ូប៊ូស្តារលក់ចេញបានថយចុះ ១២៣,០០ដុល្លារ/តោន (២,៨៥%) ដោយលក់ចេញក្នុងតម្លៃមធ្យម ៤.១៨៦,០០ដុល្លារ/តោន,FOB (ទីផ្សារ New York) និងនៅក្រុងឡុងដ៍តម្លៃកាហ្វេអារ៉ាប៊ីកាលក់ចេញបានថយ ៥៦៦,៩០ដុល្លារ/តោន (៦,៦៩%) ដោយលក់ចេញក្នុងតម្លៃមធ្យម ៧.៩០៤,១០ដុល្លារ/តោន (FOB, ទីផ្សារឡុងដុង)។ គិតជារួមក្នុងខែតុលា តម្លៃបានថយចុះ ដោយសារទីផ្សារកំពុងរង់ចាំកិច្ចប្រជុំនឹងធ្វើឡើងឆាប់ៗខាងមុខរវាងប្រធានាធិបតីអាម៉េរិក Donald Trump និងប្រធានាធិបតីប្រេស៊ីល Luiz Inacio lula da silva កិច្ចពិភាក្សាអំពីកំរិតពន្ធ ៥០% របស់អាម៉េរិកចំពោះកាហ្វេប្រេស៊ីល ដែលជាឧបសគ្គពាណិជ្ជកម្មរវាងប្រទេសទាំងពីរ។ តាមតួរលេខពីរដ្ឋាភិបាលប្រេស៊ីល ប្រទេសនេះនាំចេញ ៣,២៦លានបាវកាហ្វេ នៅក្នុងខែកញ្ញា ឆ្នាំ២០២៥ គឺថយចុះ ១៩,៥% ធៀបឆ្នាំមុន។ និងនៅប្រទេសកូឡុំប៊ី ប្រទេសផលិតកាហ្វេច្រើនបន្ទាប់ពីប្រេស៊ីល និងវៀតណាម បរិមាណផលិតផលបានកើនឡើង ១៧% ធៀបឆ្នាំមុន គឺទទួលបាន ១៤,៨៧លានបាវ (១បាវ=៦០គីឡូក្រាម) នៅចន្លោះខែតុលា-ឆ្នាំ២០២៤ ដល់ខែកញ្ញា-២០២៥ បានកើនឡើងលើសពីការព្យាករណ៍ប្រចាំឆ្នាំចំនួន ១៤លានបាវ។ ប្រទេសកូឡុំប៊ីមានផ្ទៃដីដាំកាហ្វេចំនួន ៨៤០០០០ហិចតា និងកសិករដាំដុះចំនួន ៥៤០០០០គ្រួសារ បរិមាណនាំចេញក្នុងខែកញ្ញាកើន ៦% ស្មើ ១,០៦លនបាវ។
- **ផលិតផលឧស្សាហកម្ម៖**

(ឯកតា៖ដុល្លារអាម៉េរិក/តោន)

| **មុខទំនិញ** | **លក្ខខណ្ឌ ប្រគល់-ទទួល** | **ខែសីហា ឆ្នាំ២០២៥** | **ខែកញ្ញា ឆ្នាំ២០២៥** | **កើន(+) ថយ(-)** | **ភាគរយ (%)** |
|---|---|---|---|---|---|
| ស្ករស | CIF, London | 467.80 | 468.30 | 7.1 | ▲ 1.54 |

| មុខទំនិញ | លក្ខខណ្ឌ ប្រគល់-ទទួល | ខែសីហា ឆ្នាំ២០២៥ | ខែកញ្ញា ឆ្នាំ២០២៥ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|
| កៅស៊ូប្រភេទ RSS3 | FOB, Bangkok | 2,254.64 | 2,100.00 | -50 | ▼ 2.33 |
| កៅស៊ូប្រភេទ RSS3 | FOB, Sang hai | 2,024.64 | 2,110.36 | -121.14 | ▼ 5.43 |
| កៅស៊ូប្រភេទ RSS3 | FOB, Malaysia | 2,160.00 | 2,060.00 | -40 | ▼ 1.90 |
| កៅស៊ូប្រភេទ SMRCV | FOB, Indonesia | 1,750.00 | 1,750.00 | - | - |
| កៅស៊ូប្រភេទ SIR 20 | FOB, Indonesia | 1,710.00 | 1,710.00 | - | - |

- កត់សំគាល់៖ តម្លៃទំនិញឧស្សាហកម្មមានការប្រែប្រួលទៅតាមប្រភេទនីមួយៗ ពិសេសតម្លៃស្ករស និងតម្លៃកៅស៊ូធម្មជាតិនៅក្នុងខែ តុលា ឆ្នាំ ២០២៥ ។
- តម្លៃស្ករស៖នៅក្នុងខែតុលា នៅទីផ្សារឡុងដ៍ តម្លៃស្ករសលក់ចេញបានកើនឡើងជាមធ្យម ៧,១០ដុល្លារ/តោន (១,៥៤%) ធៀបទៅនឹងខែមុនដោយលក់ចេញក្នុងតម្លៃ ៤៦៨,៣០ ដុល្លារ/តោន (FOB, ឡុងដុង)។ តាមព័ត៌មានពីក្រុមហ៊ុន ADM Investor Services បានឲ្យដឹងថា តម្លៃស្ករអាចនឹងមានលំនឹង លក្ខណៈបច្ចេកទេស, ប្រភពផ្គត់ផ្គង់សំបូរបែបពីប្រទេសប្រេស៊ីល និង សេចក្តីប្រកាសអំពីឥណ្ឌានឹងចាប់ផ្តើមប្រើប្រាស់ពោតក្នុងស្រុកធ្វើជាវត្ថុធាតុដើមដើម្បីផលិតអេតាណុល។ ទីផ្សារស្ករពិភពលោកច្រើនប្រមូលផ្តុំនៅប្រទេសផលិតច្រើន ដូចជា ប្រទេសប្រេស៊ីល (ជាប្រទេសផលិត និងនាំចេញស្ករច្រើនបំផុតលើពិភពលោក គឺជណ្តើមបានចំនួន ២០% និងជាង ៤០% បរិមាណនាំចេញ) និងឥណ្ឌា ហើយប្រេស៊ីលនាំមុខអំពីបរិមាណផលិត និងនាំចេញ ហើយការផលិតស្ករពីដើមអំពៅមានចំនួន ៧៩% និងមើមស្ពៃ។ ទីផ្សារងាយរងផលប៉ះពាល់ពីកត្តាផ្គត់ផ្គង់-តម្រូវការប្រើប្រាស់, គោលនយោបាយពាណិជ្ជកម្ម និងការប្រែប្រួលអាកាសធាតុ។ បើតាមការព្យាករណ៍របស់ Green Poolប្រភពផ្គត់ផ្គង់ស្ករពិភពលោកនឹងកើនឡើងលើសពីតម្រូវការនៅរដូវឆ្នាំ២០២៥-២៦ (ពីខែតុលា ឆ្នាំ២០២៥ ដល់ខែកញ្ញា ឆ្នាំ២០២៦) ខណៈបរិមាណផលិតផលកើនឡើង ២,៧លានតោន ធៀបទៅនឹងការខ្វះខាត ៣,៧លានតោននៅរដូវឆ្នាំមុន ហើយកំរិតនៃការប្រើប្រាស់នឹងកើន ១,២% ស្មើនឹង ១៩៨,៣លានតោន ប្រហាក់ប្រហែលរដូវមុន។
- កៅស៊ូធម្មជាតិ៖តម្លៃកៅស៊ូធម្មជាតិប្រភេទ RSS2 លក់ចេញនៅទីផ្សារតូក្យូប្រទេសជប៉ុននៅក្នុងខែតុលា នេះបានថយចុះជាមធ្យម៤០,០០ដុល្លារ/តោន(១,៩០%)ធៀបខែសីហា ឆ្នាំ២០២៥ដោយលក់ចេញក្នុងតម្លៃមធ្យម២.០៦០,០០ ដុល្លារ/តោន(FOB, តូក្យូ)។ តម្លៃជ័រកៅស៊ូធម្មជាតិ បានបន្តធ្លាក់ចុះនៅលើទីផ្សារពិភពលោក។ ស្របពេលការលក់បញ្ចុះតម្លៃរថយន្តម៉ាកល្បី BYD របស់ប្រទេសចិនបានបង្កឲ្យមានការព្រួយបារម្ភ សង្គ្រាមតម្លៃអាចនឹងផ្ទុះឡើងនៅក្នុងផលិតរថយន្ត ដែលអាចជះឥទ្ធិពលដល់វិស័យផលិតសម្បកកង់រថយន្តផ្សំពីជ័រកៅស៊ូធម្មជាតិពិភពលោក (មានតម្រូវការជ័រកៅស៊ូធម្មជាតិប្រមានជា ៧០%នៃបរិមាណសរុប)។ ពេលនេះទីផ្សារនៅតែមានការព្រួយបារម្ភអំពីការផលិតរថយន្តច្រើនហួសប្រមាណរបស់ប្រទេសចិន ជាក់ស្តែងនៅក្នុងខែសីហាចំនួនរថយន្តអគ្គិសនី(EV)លក់ចេញលើពិភពលោកបានកើន១៥% ធៀបឆ្នាំមុន ដែលជាកំរិតកំនើនយឺតយ៉ាវបើគិតចាប់តាំងពីខែមករា ឆ្នាំ២០២៥។ ថ្មីៗប្រទេសមិចស៊ីកូបានប្រកាសថានឹងបង្កើនពន្ធនាំចូលរថយន្តពីប្រទេសចិន និងតំបន់អាស៊ីឡើង ៥០% បានដាក់សំពាធដល់តម្រូវការប្រើប្រាស់រថយន្តរបស់ប្រទេសចិនក្នុងរយៈពេលដ៏ខ្លីនេះ ចំនួនរថយន្តលក់ដាច់បានជះឥទ្ធិពលដល់ការផលិតរួមទាំងវត្ថុធាតុដើមពីជ័រកៅស៊ូធម្មជាតិផងដែរ។

- **ប្រេងឥន្ធនៈ**

(ឯកតា៖ដុល្លារអាម៉េរិក/តោន)

| មុខទំនិញ | លក្ខខណ្ឌប្រគល់-ទទួល | ខែសីហា ឆ្នាំ២០២៥ | ខែកញ្ញា ឆ្នាំ២០២៥ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|
| ប្រេងឆៅBrent | FOB (New York) | 65.58 | 66.19 | 0.61 | ▲ 0.93 |
| ប្រេង WTI | FOB (New York) | 61.97 | 62.53 | 0.56 | ▲ 0.90 |
| ហ្គាសGas($/mmbtu) | F0B (VN) | 3.03 | 3.34 | 0.31 | ▲ 10.23 |

- កត់សំគាល់៖ នៅក្នុងខែកញ្ញា ឆ្នាំ២០២៥ នេះ តម្លៃប្រេងឥន្ធនៈមានការប្រែប្រួលទៅតាមប្រភេទនីមួយៗនិងជាពិសេសតម្លៃប្រេងឆៅ។
- តម្លៃប្រេងឆៅ(Brent)៖ នៅទីផ្សារក្រុងញ៉ូយកតម្លៃប្រេងឆៅ Brent បានថយ ៦,០៧ដុល្លារ/ធុង(៨,៤៧%) ដោយលក់ចេញក្នុងតម្លៃជាមធ្យម ៦៥,៥៨ដុល្លារ/ធុង(FOB,London)។ តម្លៃប្រេងឆៅពិភពលោកបានថយចុះនៅក្នុងខែកញ្ញា ឆ្នាំ២០២៥ ខណៈដែលប្រភពផ្គត់ផ្គង់កើនឡើងខ្ពស់-តម្រូវការថយចុះនៅអាម៉េរិក នឹងស្ថានភាពនយោបាយឡើងកំដៅខ្លាំងនៅតំបន់មជ្ឈឹមបូព៌ា និងអឺរ៉ុបខាងកើត។ កត្តាសំខាន់ដ៏ទៃទៀត គឺបណ្តាប្រទេស OPEC+ និងបង្កើនបរិមាណផលិតផលប្រេងធ្វើអាជីវកម្មថែម ១៣៧០០០ធុង/ថ្ងៃ ចាប់ពីខែតុលា-ឆ្នាំ២០២៥។ តាមការព្យាករណ៍របស់មជ្ឈមណ្ឌលប្រេងអន្តរជាតិ(IEA)បានឲ្យដឹងថា៖ នៅក្នុងឆ្នាំ ២០២៥ ប្រភពផ្គត់ផ្គង់ប្រេងពិភពលោកនឹងមានការកើនឡើងខ្ពស់ជាងការព្យាករណ៍ដោយសារ OPEC+ និងរុស្ស៊ី។ ស្របពេលនេះតម្រូវការប្រើប្រាស់ពិភពលោកអាចនឹងមានការកើនឡើងប៉ុន្តែមិនដើរស្របទៅនឹងការផ្គត់ផ្គង់ ដែលជាមូលហេតុបណ្តាលឲ្យទីផ្សារប្រេងងាយនឹងជួបនូវវិបត្តិ។

- **លោហៈ**

(ឯកតា៖ដុល្លារអាម៉េរិក/អោន)

| មុខទំនិញ | លក្ខខណ្ឌប្រគល់-ទទួល | ខែសីហា ឆ្នាំ២០២៥ | ខែកញ្ញា ឆ្នាំ២០២៥ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|
| មាស | Hong Kong | 3,592.50 | 3,869.37 | 276.89 | ▲ 7.71 |
| មាស | London | 3,605.00 | 3,877.50 | 272.5 | ▲ 7.56 |
| មាស | New York | 3,604.00 | 3,882.00 | 278 | ▲ 7.71 |
| Platinum | - | 1,376.60 | 1,606.60 | 230 | ▲ 16.71 |
| Palladium | New York | 1,106.50 | 1,273.50 | 167 | ▲ 15.09 |
| ប្រាក់($/troy oun | London | 40.96 | 47.49 | 6.53 | ▲ 15.94 |

| | | | | | |
|---|---|---|---|---|---|
| ស្ពាន់($/tons) | FOB London | 9,898.00 | 10,595.50 | 697.5 | ▲ 7.05 |
| អាលុយមីញ៉ូម(Al) ($/tons) | - | 2,606.15 | 2,681.95 | 75.8 | ▲ 2.91 |
| ស័ង្កសី (Zinc) ($/tons) | London | 2,863.60 | 2,967.40 | 103.8 | ▲ 3.62 |
| សំណប៉ាហាំង($/tons) | - | 34,556.00 | 35,490.00 | 934 | ▲ 2.70 |
| នីកែល ($/tons) | - | 15,280.00 | 15,235.00 | -45 | 0.29 |

- កត់សំគាល់៖ នៅក្នុងខែកញ្ញា ឆ្នាំ២០២៥ នេះ តម្លៃទំនិញលោហៈ មានការប្រែប្រួលទៅតាមប្រភេទនីមួយៗជាពិសេសតម្លៃមាស។ នៅលើទីផ្សារអន្តរជាតិ តម្លៃមាសបានកើនឡើង ធៀបទៅនឹងខែសីហា ឆ្នាំ២០២៥ នៅទីក្រុងឡុងដ៍តម្លៃមាសលក់ចេញបានកើន ៣២៩,៣៣ដុល្លារ/Ounce(១០,០៥%) ដោយលក់ចេញក្នុងតម្លៃជាមធ្យម ៣.៦០៥,០០ USD/Ounce និងនៅហុងកុង តម្លៃមាសលក់ចេញកើន ៣០៤,៣៩ដុល្លារ/ធុង(៩,២៦%) ដោយលក់ចេញក្នុងតម្លៃមធ្យម ៣.៥៩២,៥០USD/Ounce។

  ប្រភព៖ Website Vinanet

# ២. អង្គបទស្រាវជ្រាវ

## ▲ យុទ្ធសាស្ត្រពង្រីក និងពិពិធកម្មទីផ្សារនាំចេញអង្ករកម្ពុជាឆ្នាំ២០២៥-២០៣០៖

ប្រទេសកម្ពុជា គឺជាប្រទេសដែលមានខឿនសេដ្ឋកិច្ចជាតិ ពឹងផ្អែកមួយភាគធំលើវិស័យកសិកម្ម និងមានប្រជាពលរដ្ឋភាគច្រើនលើសលុបរស់នៅទីជនបទ និងប្រកបរបរកសិកម្មសម្រាប់ចិញ្ចឹមជីវិត ហើយធានាបាននូវអតិរេជ្យនៃផលិតផលបំរើឲ្យការនាំចេញ។ ខណៈដែលពិភពលោកកំពុងជួបប្រទះវិបត្តិស្បៀង កម្ពុជាបានខិតខំបង្កើននូវផលិតកម្មដំណាំស្បៀង សំដៅរួមចំណែកដោះស្រាយបញ្ហានេះ ដោយសារយើងមានសក្តានុពល អំណោយផលយ៉ាងធំធេង ជាពិសេសដំណាំស្រូវ ដែលអាចពង្រីកបានទាំងផ្នែកផលិតកម្ម និងការនាំចេញ។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ នៃរាជរដ្ឋាភិបាលកម្ពុជា បានកំណត់ការលើកកម្ពស់វិស័យកសិកម្ម សំរាប់ជំរុញកំណើនសេដ្ឋកិច្ច និងពន្លឿនការកាត់បន្ថយភាពក្រីក្រ។ សំរាប់ការអភិវឌ្ឍវិស័យស្រូវអង្ករ "មាសស" រាជរដ្ឋាភិបាលកម្ពុជា មានមហិច្ឆតាចង់ឲ្យប្រទេសកម្ពុជា ក្លាយទៅជាប្រទេសនាំចេញអង្ករធំមួយប្រចាំតំបន់ សម្រាប់ផ្គត់ផ្គង់លើទីផ្សារពិភពលោក។

យោងតាមការបូកសរុបលទ្ធផលការងារ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងរដូវឆ្នាំ២០១០-២០១១ បានបង្ហាញថា ផលិតកម្មស្រូវសម្រេចបានចំនួន ៨,២៤លានតោន អាចមានអតិរេកផលស្រូវចំនួន ៣,៩លានតោន សម្រាប់កែច្នៃនាំចេញ។ ប៉ុន្តែកន្លងមក តួលេខនាំចេញផ្លូវការក្នុងឆ្នាំ២០០៩ មានតែ ១៣ពាន់តោនអង្ករ ឬ ២០ពាន់តោនស្រូវប៉ុណ្ណោះ ទោះបរិមាណស្រូវជាក់ស្តែងដែលហូរចេញពីកម្ពុជា មានកំរិតខ្ពស់ជាងនេះក្តី។ ម៉្យាងវិញទៀត ដោយសារមានការវិនិយោគកាន់តែច្រើន ក្នុងការកសាងប្រព័ន្ធធារាសាស្ត្រ និងដាំដុះស្រូវ ការពង្រីកផ្ទៃដីដាំដុះ និងប្រពលវប្បកម្ម ព្រមទាំងកំណើនទិន្នផលស្រូវ ដោយសារកត្តាប្រើប្រាស់ទឹក ពូជ និងជី ព្រមទាំងបច្ចេកទេសដាំដុះកាន់តែប្រសើរឡើង រាជរដ្ឋាភិបាលរំពឹងថា នឹងមានការកើនឡើងនូវផលិតកម្មស្រូវ ដែលនាំឲ្យកម្ពុជាកាន់តែមានអតិរេកផលស្រូវ សម្រាប់កែច្នៃជាអង្ករនាំចេញកាន់តែច្រើនក្នុងពេលខាងមុខ ប្រការនេះ បានឆ្លុះបញ្ចាំងពីសក្តានុពល សម្រាប់ជំរុញការនាំចេញអង្ករជាលក្ខណៈផ្លូវការ។

ក្រសួងពាណិជ្ជកម្មក្នុងនាមជាអាណាព្យាបាលបច្ចេកទេស ក្នុងការអនុវត្ត យុទ្ធសាស្ត្រពង្រីក និង ពិពិធកម្មទីផ្សារនាំចេញកម្ពុជាពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ផ្លូវការនៃ "យុទ្ធសាស្ត្រពង្រីក និងពិពិធកម្មទីផ្សារនាំចេញអង្ករកម្ពុជា

២០២៥-២០៣០ "និង" ពិធីមហាសន្និបាត សហព័ន្ធស្រូវអង្ករកម្ពុជាអាណត្តិទី៤ និងការបោះឆ្នោតជ្រើសរើសប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាល នៃសហព័ន្ធស្រូវអង្ករកម្ពុជា អាណត្តិទី៥"។

នាថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៥ នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងឯកឧត្តម ឌិត ទីណា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអញ្ជើញជាគណៈអធិបតីក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវ "យុទ្ធសាស្ត្រពង្រីក និងពិពិកម្មទីផ្សារនាំចេញអង្ករកម្ពុជា ២០២៥-២០៣០" និង "ពិធីមហាសន្និបាត សហព័ន្ធស្រូវអង្ករកម្ពុជា អាណត្តិទី៤ និងការបោះឆ្នោតជ្រើសរើសប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាល នៃសហព័ន្ធស្រូវអង្ករកម្ពុជា អាណត្តិទី៥" ដោយមានវត្តមានអញ្ជើញចូលរួមពីតំណាងក្រសួង-ស្ថាប័នពាក់ពន្ធ័ ថ្នាក់ដឹកនាំ និងសមាជិកសហព័ន្ធស្រូវអង្ករកម្ពុជា តំណាងអង្គការស្បៀង និងកសិកម្មនៃអង្គការសហប្រជាជាតិប្រចាំកម្ពុជា អង្គការដៃគូអភិវឌ្ឍន៍ តំណាងសភាពាណិជ្ជកម្មអន្តរជាតិប្រចាំកម្ពុជា ព្រមទាំងតំណាងសមាគម និងអង្គការក្រៅរដ្ឋាភិបាលជាច្រើនរូប។ ជាកិច្ចចាប់ផ្តើម លោកជំទាវរដ្ឋមន្ត្រី បានសម្តែងនូវការកោតសរសើរ និងការវាយតម្លៃខ្ពស់ចំពោះសហព័ន្ធស្រូវអង្ករកម្ពុជា និងការចាត់ទុកថាព្រឹត្តិការណ៍ដែលបានរៀបចំនេះ គឺជាព្រឹត្តិការណ៍នៃកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូរ រវាងក្រសួងពាណិជ្ជកម្ម សហព័ន្ធស្រូវអង្ករកម្ពុជា និងអង្គការស្បៀង និងកសិកម្មនៃអង្គការសហប្រជាជាតិ(FAO) ក៏ដូចជាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូពាក់ព័ន្ធដទៃទៀត។

តាមរយៈការដាក់ចេញនូវ "យុទ្ធសាស្ត្រពង្រីក និងពិពិកម្មទីផ្សារនាំចេញអង្ករកម្ពុជា ២០២៥-២០៣០" នេះ លោកជំទាវរដ្ឋមន្ត្រី បានគូសរំលេចនូវទិសដៅចម្បងៗចំនួន៣៖ ១-រក្សាជំហររឹងមាំរបស់កម្ពុជា លើទីផ្សារអង្ករក្រអូបសំខាន់ៗលើទីផ្សារអន្តរជាតិ ២- បង្កើនការនាំចេញអង្ករសប្រណិតដោយផ្តោតលើក្រុមប្រជាជនដែលមានចំណូលមធ្យមនៅក្នុងទីផ្សារតំបន់អាស៊ី និង ៣- ពង្រឹងឱកាសទីផ្សារឲ្យទូលាយបន្ថែមទៀត តាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មដែលមានស្រាប់ និងពេលអនាគត ក៏ដូចជាតាមរយៈយន្តការលទ្ធកម្មស្បៀងអាហារតាមស្ថាប័ន ដូចជា តាមរយៈយន្តការកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាល និងរដ្ឋាភិបាល (G2G) កម្មវិធីជំនួយស្បៀងអាហារ និងលទ្ធកម្មសន្តិសុខស្បៀងដោយអង្គការសហប្រជាជាតិ និងអង្គការមនុស្សធម៌នានា។ ទន្ទឹមនេះដែរ លោកជំទាវរដ្ឋមន្ត្រី ក៏បានបន្តទៀតថា ក្នុងឆ្នាំ២០២៤ កន្លងទៅកម្ពុជាសម្រេចបាននូវការរីកចម្រើនលើការនាំចេញទៅទីផ្សារចិន ដែលគ្របដណ្តប់លើបរិមាណនាំចេញសរុបរហូតដល់៣០% ហើយក្នុងឆ្នាំ២០២៥នេះ នឹងបន្តកើនឡើងថែមទៀត ដោយមានមូលដ្ឋាននៃការប្តេជ្ញាចិត្តខ្ពស់ប្រទេសចិន តាមរយៈការចុះអនុស្សរណៈយោគយល់គ្នាលើកទី៧ ចំនួន ៥០ម៉ឺនតោន។ ហើយក្នុងនីតិកាលទី៧នេះ ក្រសួងពាណិជ្ជកម្ម នឹងបន្តផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការចូលរួមដោយមិនអាចខ្វះបានរបស់វិស័យឯកជន ក្នុងការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាល និងទាញយកផលប្រយោជន៍ជាអតិបរមាពីកិច្ចព្រមព្រៀងកម្ពុជាជាសមាជិក។ ក្នុងនោះ លោកជំទាវរដ្ឋមន្ត្រី ក៏បានសង្កត់ធ្ងន់លើតួនាទីសំខាន់របស់សហព័ន្ធស្រូវអង្ករកម្ពុជា ក្នុងការចូលរួមជាមួយ ក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាពិសេសជាមួយក្រសួងពាណិជ្ជកម្មក្នុងនាមជាអាណាព្យាបាលបច្ចេកទេសក្នុងការអនុវត្ត "យុទ្ធសាស្ត្រពង្រីក និងពិពិកម្មទីផ្សារនាំចេញអង្ករកម្ពុជា ២០២៥-២០៣០" និងបានផ្តល់នូវអនុសាសន៍គន្លឹះមួយចំនួន ដល់សហព័ន្ធស្រូវអង្ករកម្ពុជា ក្រុមហ៊ុននាំចេញ និងភាគីពាក់ព័ន្ធ ដើម្បីជាទិសដៅការងារសម្រាប់បន្តអនុវត្តដូចខាងក្រោម៖

-ត្រូវចូលរួមប្រតិបត្តិការជំនួញ-ធុរកិច្ចស្របតាមច្បាប់ជាធរមាន ប្រកាន់ខ្ជាប់នូវក្រមសីលធម៌ប្រកបដោយតម្លាភាព ផ្គត់ផ្គង់ប្រភេទអង្ករដែលមានលក្ខណៈប្រកួតប្រជែង ការពារផលប្រយោជន៍របស់ភាគីពាក់ព័ន្ធ និងបង្កើនភាពជឿជាក់នៃអង្ករកម្ពុជានៅលើទីផ្សារជាតិ និងអន្តរជាតិ ។

-ត្រូវចូលរួមពង្រឹងគុណភាពអង្ករកម្ពុជាប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដោយត្រូវគិតគូរទាំងបរិមាណគុណភាពសុវត្ថិភាព និងសោភ័ណភាព នៃការវេចខ្ចប់តាមស្តង់ដាត្រឹមត្រូវ ដើម្បីរក្សាបាននូវកេរ្តិ៍ឈ្មោះអង្ករកម្ពុជា និងនិរន្តរភាពនៃការនាំចេញ។

-ត្រូវធានាជាមួយភាគីអ្នកទិញ ឬតម្រូវឲ្យមានធានារ៉ាប់រងលើការធានាគុណភាពម៉ាកអង្ករកម្ពុជា។

-ត្រូវបន្ថែមការប្រុងប្រយ័ត្នលើការប្រើប្រាស់សារធាតុទាំងសមស្រប និងមិនសមស្រប បរិមាណលើសកំណត់ ស្របទៅតាមបទដ្ឋាន និង ស្តង់ដារបស់ប្រទេសនាំចូល ។

-បន្តចូលរួមយ៉ាងសកម្មជាមួយក្រសួងពាណិជ្ជកម្ម ក្នុងការចរចាពង្រីកទីផ្សារនាំចេញ និងការសម្របសម្រួលលើអនុស្សរណៈនៃការយោគយល់នៃការយោគយល់គ្នា ដើម្បីនាំអង្ករចេញទៅកាន់ទីផ្សារក្រៅប្រទេស ។ នាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៥ លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានអញ្ជើញជាអធិបតីក្នុងពិធីបើកកម្មវិធីខួបទី១០ នៃ

ការបង្កើតសហព័ន្ធស្រូវអង្ករកម្ពុជា ដែលប្រារព្ធឡើងនៅ The Premier Center Sen Sok ជាកិច្ចចាប់ផ្តើម លោកជំទាវរដ្ឋមន្ត្រី បានសម្តែងនូវការកោតសរសើរ និងការវាយតម្លៃខ្ពស់ចំពោះសហព័ន្ធស្រូវអង្ករកម្ពុជា និងភាគីពាក់ព័ន្ធទាំងអស់ដែលសម្រេចបាននូវសមិទ្ធផលគួជាទីមោទនៈនាពេលកន្លងមក និងបានលើកឡើងអំពីអត្ថប្រយោជន៍របស់ដំណាំស្រូវ ដែលជាដំណាំយុទ្ធសាស្ត្ររបស់កម្ពុជាសម្រាប់សន្តិសុខស្បៀង និងជាអាហាររូបត្ថម្ភ ដោយមិនត្រឹមតែជាអាហារមូលដ្ឋានដ៏ចាំបាច់ប៉ុណ្ណោះទេ ថែមទាំងជាទំនិញនាំចេញដ៏មានសក្តានុពលក្នុងចំណោមបញ្ជីផលិតផលកសិកម្មដែលបានធ្វើការជ្រើសរើសជាអាទិភាពសម្រាប់ជំរុញការនាំចេញ។ ក្នុងឱកាសនោះលោកជំទាវរដ្ឋមន្ត្រី បានគូសបញ្ជាក់ថាសហព័ន្ធស្រូវអង្ករកម្ពុជា ត្រូវបានបង្កើតឡើងដោយក្រសួងពាណិជ្ជកម្មក្នុងគោលបំណងដើម្បីចូលរួមគាំទ្រការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្កររបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញដោយ សម្តេចអគ្គមហាសេនាធិបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈការបោះឆ្នោត នាថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ ហើយត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ចេញអនុក្រឹត្រលេខ ២២៨ អនក្រ.បក ចុះថ្ងៃ ទី៨ ខែសីហា ឆ្នាំ២០១៤ ទទួលស្គាល់សហព័ន្ធស្រូវអង្ករកម្ពុជា ជាដៃគូតែមួយសម្រាប់ពិភាក្សាគោលនយោបាយ និងជាអ្នកតំណាងវិស័យស្រូវអង្ករកម្ពុជាលើឆាកអន្តរជាតិ។ លោកជំទាវរដ្ឋមន្ត្រី បានបន្តទៀតថា ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជា ជាមួយនឹងកិច្ចខិតខំប្រឹងប្រែងរួមគ្នាពីសហព័ន្ធស្រូវអង្ករកម្ពុជា ដៃគូរអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធនានា កម្ពុជាបានប្រែក្លាយខ្លួនទៅជាប្រទេស ដែលមានអតិរេកស្រូវអង្ករច្រើន។ ជាក់ស្តែងនៅដើមនីតិកាលទី៧នេះ ក្រសួងពាណិជ្ជកម្ម បានជំរុញឲ្យមានការរៀបចំ និងចុះអនុស្សរណៈយោគយល់គ្នានាំចេញអង្ករទៅកាន់ប្រទេសចិនចំនួន ៥០ ម៉ឺនតោន។ ទន្ទឹមនឹងនោះ ការបើកច្រកទីផ្សារនាំចេញទៅកាន់ប្រទេសឥណ្ឌូនេស៊ីតាមរយៈក្រុមហ៊ុនហ្គ្រីនត្រេដ របស់ក្រសួងពាណិជ្ជកម្មចំនួន ៣៧៥០០តោន និងប្រទេសទីម័រលេស្តេរចំនួន ៤០០០តោន ហើយលើសពីនេះ នៅក្នុងឆ្នាំ ២០២៤ កម្ពុជាបាននាំចេញអង្ករចំនួនជា ៦៥០០០០តោន ទៅកាន់ប្រទេសចំនួន ៧៥ ហើយកន្លងមក តាមរយៈក្រុមហ៊ុនហ្គ្រីនត្រេដក្រសួងពាណិជ្ជកម្ម បាននិងកំពុងបន្តការចរចារជាមួយបណ្តាប្រទេសមួយចំនួនដើម្បីពង្រីកទីផ្សារអង្ករកម្ពុជា។

មុននឹងបញ្ចប់ លោកជំទាវរដ្ឋមន្ត្រី បានផ្តល់នូវអនុសាសន៍គន្លិះមួយចំនួនដល់សហព័ន្ធស្រូវអង្ករកម្ពុជា ក្រុមហ៊ុននាំចេញ និងភាគីពាក់ព័ន្ធទាំងអស់ ដើម្បីចូលរួមលើកកម្ពស់វិស័យស្រូវអង្ករកម្ពុជាឲ្យកាន់តែមានភាពរីកចំរើនរួមមាន៖ ១-ត្រូវពិនិត្យលទ្ធភាព ទាក់ទាញវិនិយោគិនបន្ថែមទៀត មកចូលរួមបណ្តាក់ទុនក្នុងផលិតកម្ម និងលើកកម្ពស់តម្លៃបន្ថែមលើគុណភាពខ្សែច្រវាក់ផលិតកម្មអង្ករ ដើម្បីបម្រើការផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងឈានទៅបង្កើនឧត្តមភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងពាណិជ្ជកម្មអន្តរជាតិ។ ២-ចូលរួមប្រតិបត្តិការជំនួញ-ធុរៈកិច្ចស្របតាមជាធរមាន ប្រកាន់ខ្ជាប់នូវក្រមសីលធម៌ ប្រកមដោយតម្លាភាព ផ្គត់ផ្គង់អង្ករដែលមានលក្ខណៈប្រកួតប្រជែង ការពារផលប្រយោជន៍របស់ភាគីពាក់ព័ន្ធ និងបង្កើនភាពជឿជាក់នៃអង្ករកម្ពុជានោលើទីផ្សារជាតិ និងអន្តរជាតិ។ ៣-ចូលរួមលើកកម្ពស់ និងការពារម៉ាកនិងកម្មសិទ្ធិបញ្ញា ជាពិសេស ការកសាងម៉ាកសមូហភាព និងការពង្រឹងគុណភាពអង្ករកម្ពុជា ដោយត្រូវគិតគួរទាំងបរិមាណ គុណភាព សុវត្ថិភាព និងសោភ័ណភាពនៃការវេចខ្ចប់តាមស្តង់ដាត្រឹមត្រូវ ដើម្បីរក្សាបាននូវកេរ្តិ៍ឈ្មោះអង្ករកម្ពុជា និងនិរន្តភាពនៃការនាំចេញ។ ៤- បន្តសហការជាមួយអគ្គនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងពាណិជ្ជកម្ម ជាពិសេសក្រុមហ៊ុនហ្គ្រីនត្រេដ ក្រុមការងារជំរុញការនាំចេញ និងដៃគូរពាក់ព័ន្ធ ក្នុងការអនុវត្តវិធានការបង្កើនប្រសិទ្ធភាព និងគុណភាព ដើម្បីពង្រឹងទីផ្សារដែលមានស្រាប់ និងពង្រីកទីផ្សារថ្មីបន្ថែមទៀត សំដៅបង្កើនការផ្គត់ផ្គង់ក្នុងស្រុក និងបង្កើនការនាំចេញអង្ករទៅកាន់ទីផ្សារអន្តរជាតិ។ ៥-ធ្វើទំនើបនីយកម្មរចនាសម្ព័ន្ធប្រតិបត្តិការ នីតិវិធីការងារ ដំណើរការប្រព្រឹត្តទៅ និងលក្ខន្តិកៈសហព័ន្ធជាដើម។

ការតាំងចិត្តយ៉ាងមុតមាំក្នុងការអនុវត្ត និងជំនះនូវរាល់ឧបសគ្គ ពីគ្រប់ស្រទាប់ថ្នាក់ដឹកនាំក្រសួងពាក់ពន្ធ រួមទាំងការបង្កើននូវថវិកាចំណាយរបស់រដ្ឋ ដូចជាការចូលរួមចំណែកដោយពេញចិត្តពេញថ្លើមពីសំណាក់ប្រជាកសិករ ពិតជានឹងប្រែក្លាយផែនការសកម្មភាព ឲ្យទៅជាការអនុវត្តជាក់ស្តែង ដើម្បីទទួលបាននូវលទ្ធផលប្រកបដោយផ្លែផ្កា និងមានប្រសិទ្ធភាពខ្ពស់ ហើយឈានទៅសម្រេចបាននូវទិសដៅគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលបានកំណត់នេះ។

ប្រភព៖ អត្ថបទស្រាវជ្រាវ

# ៣. ព័ត៌មានរបស់ក្រសួងពាណិជ្ជកម្ម

### លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានតំណាងកម្ពុជា បានដឹកនាំគណៈប្រតិភូកម្ពុជា ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន និងអគ្គនាយកអង្គការកម្មសិទ្ធិបញ្ញាពិភពលោក នៅរដ្ឋធានីគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី

(គូឡាឡាំពួ, ម៉ាឡេស៊ី)៖ នាព្រឹកថ្ងៃពុធ ទី២៤ ខែកញ្ញា ឆ្នាំ២០២៥ លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានតំណាងកម្ពុជា បានដឹកនាំគណៈប្រតិភូកម្ពុជា ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន និងអគ្គនាយកអង្គការកម្មសិទ្ធិបញ្ញាពិភពលោក នៅរដ្ឋធានីគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី។

កិច្ចប្រជុំនេះត្រូវបានរៀបចំឡើងស្របនឹងកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៥៧ ក្រោមភាពជាប្រធានអាស៊ានរបស់ប្រទេសម៉ាឡេស៊ី ឆ្នាំ២០២៥ ក្នុងគោលបំណងពិភាក្សាលើបច្ចុប្បន្នភាពនៃកិច្ចការកម្មសិទ្ធិបញ្ញារបស់អាស៊ាន វឌ្ឍនភាពនៃការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងអាស៊ាន-អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ផែនការសកម្មភាពស្តីពីសិទ្ធិកម្មសិទ្ធិបញ្ញាអាស៊ាន ឆ្នាំ២០២៦-២០៣០ និងការដាក់ចេញនូវការដាក់បញ្ចូលទិន្នន័យនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញា។

សូមចូលអានព័ត៌មានលំអិតតាមរយៈ https://moc.gov.kh/en-US/news/3429

### លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានតំណាងកម្ពុជា បានដឹកនាំគណៈប្រតិភូកម្ពុជា ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន-សាធារណរដ្ឋកូរ៉េ លើកទី២២ នៅរដ្ឋធានីគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី

(គូឡាឡាំពួ, ម៉ាឡេស៊ី)៖ នាព្រឹកថ្ងៃពុធ ទី២៤ ខែកញ្ញា ឆ្នាំ២០២៥ លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានតំណាងកម្ពុជា បានដឹកនាំគណៈប្រតិភូកម្ពុជា ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន-សាធារណរដ្ឋកូរ៉េ លើកទី២២ នៅរដ្ឋធានីគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី។

កិច្ចប្រជុំនេះត្រូវបានរៀបចំឡើងស្របនឹងកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៥៧ ក្រោមភាពជាប្រធានអាស៊ានរបស់ប្រទេសម៉ាឡេស៊ី ឆ្នាំ២០២៥ ក្នុងគោលបំណងតាមដាន និងពិភាក្សាលើវឌ្ឍនភាពនៃការអនុវត្តកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-សាធារណរដ្ឋកូរ៉េ (AKFTA) កម្មវិធីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ាន-សាធារណរដ្ឋកូរ៉េ និងការត្រៀមរៀបចំដំឡើងកម្រិតកិច្ចព្រមព្រៀង AKFTA។

សូមចូលអានព័ត៌មានលំអិតតាមរយៈ https://moc.gov.kh/en-US/news/3430

### លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានជួបពិភាក្សាការងារជាមួយ ឯកឧត្តម Yan Dong អនុរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម នៃសាធារណរដ្ឋប្រជាមានិតចិន

(គូឡាឡាំពួ, ម៉ាឡេស៊ី)៖ នាព្រឹកថ្ងៃពុធ ទី២៤ ខែកញ្ញា ឆ្នាំ២០២៥ លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានជួបពិភាក្សាការងារជាមួយ ឯកឧត្តម Yan Dong អនុរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម នៃសាធារណរដ្ឋប្រជាមានិតចិន ។

ក្នុងជំនួបនេះ ភាគីទាំងពីរបានពិភាក្សាលើយន្តការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មទ្វេភាគីឱ្យកាន់តែរីកចម្រើនបន្ថែមទៀត ជាពិសេសការទាញយកអត្ថប្រយោជន៍ជាអតិបរមាពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន។

(Kuala Lumpur): On the morning of Wednesday, 24 September 2025, Her Excellency CHAM Nimul, Minister of Commerce, had a courtesy call meeting with His Excellency Yan Dong, Vice Minister of Commerce of the People’s Republic of China.

During the meeting, both sides discussed mechanisms to strengthen and further expand bilateral trade cooperation, with a particular focus on maximizing the benefits of the Cambodia–China Free Trade Agreement.

សូមចូលអានព័ត៌មានលំអិតតាមរយៈ https://moc.gov.kh/en-US/news/3431

## លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងគណៈប្រតិភូក្រសួងពាណិជ្ជកម្ម បានអញ្ជើញចូលរួមកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីឆ្លងសេចក្តីព្រាងច្បាប់ចំនួន ៥

(ភ្នំពេញ)៖ នាព្រឹកថ្ងៃសុក្រ ទី២៦ ខែកញ្ញា ឆ្នាំ២០២៥ នៅវិមានសន្តិភាព លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងគណៈប្រតិភូក្រសួងពាណិជ្ជកម្ម បានអញ្ជើញចូលរួមកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីឆ្លងសេចក្តីព្រាងច្បាប់ ចំនួន ៥ រួមមាន៖

១-សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីក្របខ័ណ្ឌបទប្បញ្ញត្តិសុវត្ថិភាពម្ហូបអាហារអាស៊ាន។
២-សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងអាស៊ានស្តីពីបម្លាស់ទីរូបវន្តបុគ្គល។
៣-សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទីមួយធ្វើវិសោធនកម្មកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន។
៤-សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទីពីរធ្វើវិសោធនកម្មកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់។
៥-សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីការបង្កើតអង្គការអន្តរជាតិសម្រាប់សន្ទានកម្ម។

ជាលទ្ធផល សេចក្តីព្រាងច្បាប់ទាំង ៥ ខាងលើត្រូវបានឯកភាពដើម្បីបន្តនីតិវិធីដើម្បីដាក់ឆ្លងទៅស្ថាប័ននីតិបញ្ញត្តិទាំងពីរ ដើម្បីពិនិត្យ និងអនុម័ត។

សូមចូលអានព័ត៌មានលំអិតតាមរយៈ https://moc.gov.kh/en-US/news/3454

## ឯកឧត្តម ពេជ ឫទ្ធី រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម តំណាងដ៏ខ្ពង់ខ្ពស់របស់ លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានតំណាងកម្ពុជា បានដឹកនាំគណៈប្រតិភូកម្ពុជា ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន-ការិយាល័យតំណាងពាណិជ្ជកម្មអាម៉េរិក (AEM-USTR Consultation) និងកិច្ចប្រជុំពិគ្រោះយោបល់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន-រដ្ឋមន្ត្រីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្មនៃប្រទេសជប៉ុន លើកទី៣១ (31st AEM-METI Consultation) នៅរដ្ឋធានីគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី

(គូឡាឡាំពួ, ម៉ាឡេស៊ី)៖ នារសៀលថ្ងៃពុធ ទី២៤ ខែកញ្ញា ឆ្នាំ២០២៥ ឯកឧត្តម ពេជ ឫទ្ធី រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម តំណាងដ៏ខ្ពង់ខ្ពស់របស់ លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានតំណាងកម្ពុជា បានដឹកនាំគណៈប្រតិភូកម្ពុជា ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន-ការិយាល័យតំណាងពាណិជ្ជកម្មអាម៉េរិក (AEM-USTR Consultation) និងកិច្ចប្រជុំពិគ្រោះយោបល់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន-រដ្ឋមន្ត្រីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្មនៃប្រទេសជប៉ុន លើកទី៣១ (31st AEM-METI Consultation) នៅរដ្ឋធានីគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី។

កិច្ចប្រជុំទាំងពីរខាងលើត្រូវបានរៀបចំឡើងស្របនឹងកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៥៧ ក្រោមភាពជាប្រធានអាស៊ានរបស់ប្រទេសម៉ាឡេស៊ី ឆ្នាំ២០២៥ ដើម្បីតាមដាន និងពិនិត្យលើវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរវាងអាស៊ាន ជាមួយនឹងសហរដ្ឋអាមេរិក និងជប៉ុន ក្រោមក្របខណ្ឌអាស៊ាន។

សូមចូលអានព័ត៌មានលំអិតតាមរយៈ https://moc.gov.kh/en-US/news/3467

## ឯកឧត្តម ពេជ ឫទ្ធី រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម តំណាងដ៏ខ្ពង់ខ្ពស់របស់ លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានតំណាងកម្ពុជា បានដឹកនាំគណៈប្រតិភូកម្ពុជា ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន ជាមួយនឹងប្រទេសដៃគូអាស៊ាន

(គូឡាឡាំពួ, ម៉ាឡេស៊ី)៖ នាថ្ងៃព្រហស្បតិ៍ ទី២៥ ខែកញ្ញា ឆ្នាំ២០២៥ នៅរដ្ឋធានីគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី ឯកឧត្តម ពេជ ឫទ្ធី រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម តំណាងដ៏ខ្ពង់ខ្ពស់របស់ លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានតំណាងកម្ពុជា បានដឹកនាំគណៈប្រតិភូកម្ពុជា ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន ជាមួយនឹងប្រទេសដៃគូអាស៊ាន ដូចខាងក្រោម៖

- កិច្ចប្រជុំពិគ្រោះយោបល់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់ លើកទី៣០ (30th AEM-CER)
- កិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចនៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ា លើកទី១៣ (13th EAS-EMM)
- ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន-ចក្រភពអង់គ្លេស លើកទី៥ (5th AEM-UK)
- កិច្ចប្រជុំពិគ្រោះយោបល់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន-ស្នងការពាណិជ្ជកម្មសហភាពអឺរ៉ុប លើកទី២១ (21st AEM-EU Trade Commissioner Consultation)

កិច្ចប្រជុំខាងលើត្រូវបានរៀបចំឡើងស្របនឹងកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី ៥៧ ក្រោមភាពជាប្រធានអាស៊ានរបស់ប្រទេសម៉ាឡេស៊ី ឆ្នាំ២០២៥ ដើម្បីតាមដាន និងពិនិត្យលើវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរវាងអាស៊ាន ជាមួយនឹងដៃគូខាងលើ ក្រោមក្របខណ្ឌអាស៊ាន ក៏ដូចជាតាមដានការអនុវត្តកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់ (AANZFTA) ផងដែរ។

សូមចូ លអានព័ត៌មានលំអិតតាមរយៈ https://moc.gov.kh/en-US/news/3468

## ឯកឧត្តម ពេជ ឫទ្ធី រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម តំណាងដ៏ខ្ពង់ខ្ពស់របស់ លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានតំណាងកម្ពុជា បានដឹកនាំគណៈប្រតិភូកម្ពុជា ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន ជាមួយនឹងប្រទេសដៃគូអាស៊ាន

(គូឡាឡាំពួ, ម៉ាឡេស៊ី)៖ នាថ្ងៃសុក្រ ទី២៦ ខែកញ្ញា ឆ្នាំ២០២៥ នៅរដ្ឋធានីគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី ឯកឧត្តម ពេជ ឫទ្ធី រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម តំណាងដ៏ខ្ពង់ខ្ពស់របស់ លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានតំណាងកម្ពុជា បានដឹកនាំគណៈប្រតិភូកម្ពុជា ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន ជាមួយនឹងប្រទេសដៃគូអាស៊ាន ដូចខាងក្រោម៖

-កិច្ចប្រជុំពិគ្រោះយោបល់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន-ត្រីភាគីជាមួយរដ្ឋមន្ត្រីពាណិជ្ជកម្មស្វីស លើកទី៤ (4th AEM-Troika Open-ended Dialogue with Switzerland Trade Minister)

-កិច្ចប្រជុំពិគ្រោះយោបល់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន-កាណាដា លើកទី១៤ (14th AEM-Canada Consultation)

-កិច្ចប្រជុំពិគ្រោះយោបល់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន-ឥណ្ឌា លើកទី២២ (22nd AEM-India Consultation)

-កិច្ចប្រជុំពិគ្រោះយោបល់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន-រុស្ស៊ី លើកទី១៤ (14th AEM-Russia Consultation)

-កិច្ចប្រជុំពិគ្រោះយោបល់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន-ហុងកុងនៃប្រទេសចិន លើកទី៩ (9th AEM-Hong Kong of China Consultation)

កិច្ចប្រជុំខាងលើត្រូវបានរៀបចំឡើងស្របនឹងកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី ៥៧ ក្រោមភាពជាប្រធានអាស៊ានរបស់ប្រទេសម៉ាឡេស៊ី ឆ្នាំ២០២៥ ដើម្បីតាមដាន និងពិនិត្យលើវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរវាងអាស៊ាន ជាមួយនឹងដៃគូខាងលើ ក្រោមក្របខណ្ឌអាស៊ាន ការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុងនៃប្រទេសចិន (AHKFTA) ព្រមទាំងវឌ្ឍនភាពនៃការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កាណាដា (ACAFTA) និងការពិនិត្យឡើងវិញកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន-ឥណ្ឌា (AITIGA) ផងដែរ។

សូមចូលអានព័ត៌មានលំអិតតាមរយៈ https://moc.gov.kh/en-US/news/3470

# ៤.ព័ត៌មានទីផ្សារអន្តរជាតិ

## ▲ ទីផ្សារនាំចេញទំនិញវៀតណាមមកកម្ពុជា ៧ខែដើមឆ្នាំ២០២៥៖

ក្នុងបណ្តាឆ្នាំកន្លងទៅ កិច្ចសហប្រតិសេដ្ឋកិច្ច ពាណិជ្ជម្មរវាងកម្ពុជា វៀតណាម ទទួលបាននូវសមិទ្ធិផលល្អប្រសើរ និងប្រកបដោយអត្ថន័យជ្រាលជ្រៅ ហើយទន្ទឹមនោះវៀតណាម ក៏ជាដៃគូរពាណិជ្ជកម្មលំដាប់ទីមួយរបស់កម្ពុជាផងដែរ។ តាមតួរលេខថ្មីបំផុតរបស់នាយកដ្ឋានគយវៀតណាមបានអោយដឹងថា នៅក្នុងរយៈពេល៧ខែដើម ឆ្នាំ២០២៥ ទំនិញនាំចូលពីវៀតណាមមកកម្ពុជា គិតជាទឹកប្រាក់មានចំនួន ៣,២ពាន់លានដុល្លារ គឺកើនឡើង ៥,៧% ធៀបរយៈពេលដូចគ្នាឆ្នាំមុន។ មុខទំនិញវាយនភ័ណ្ឌគឺជាមុខទំនិញនាំមុខក្នុងចំណោមមុខទំនិញនាំចូលទៅកាន់ទីផ្សារកម្ពុជា នៅក្នុងខែកក្កដា ឆ្នាំ២០២៥ ដោយទទួលបានទឹកប្រាក់សរុបចំនួន ៨៦,៥០លានដុល្លារ គឺកើន ២៣,២% ធៀបខែបន្ទាប់ នឹង៧ខែដើមឆ្នាំ ទទួលបានបាន ៥៣៣,១ លានដុល្លារ កើន ៧,៥០% ដណ្តើមបាន ១៦,៤% នៃបរិមាណទំនិញនាំចេញសរុប។ មុខទំនិញបន្ទាប់ គឺដែកគ្រប់ប្រភេទ បើគិតជារួមនៅក្នុងខែកក្កដា ឆ្នាំ២០២៥ ទទួលបានទឹកប្រាក់សរុប ៧០,១លានដុល្លារ គឺបានថយ ៨,៧% ធៀបខែមុន និង៧ខែដើមឆ្នាំ ទទួលបាន៥០៨,០០លានដុល្លារអាមេរិក កើន ១៨,៩% ស្មើនឹង ១៥,៦% នៃទំនិញនាំចេញសរុប។ ក្នុងរយៈពេល៧ខែដើមឆ្នាំ២០២៥ បណ្តាមុខទំនិញនាំចេញដែលទទួលបានកំណើនធៀបទៅនឹងរយៈពេលដូចគ្នារួមមាន៖ ផលិតផលពីដែកថែមកើន ៣១,៧% ចំណីសត្វ និងវត្ថុធាតុដើមកើន ៤៤,២% បន្លែផ្លែឈើកើន ៥៧% កាហ្វេកើន ១១៤,៨% ។

វៀតណាម និងកម្ពុជាមានវប្បធម៌ប្រពៃណីតម្រូវការទីផ្សារ របៀបរបបនៃការរស់នៅ ប្រហាក់ប្រហែលគ្នា ដែលជាកត្តាផ្តល់អំណោយយ៉ាងច្រើនដល់ទំនិញ សេវាកម្មរបស់វៀតណាមត្រូវបានស្វាគមន៍នៅលើទីផ្សារកម្ពុជា។ ជាមួយនឹងកិច្ចសហប្រតិបត្តិកាទ្វេភាគី រាល់បណ្តាកិច្ចព្រមព្រៀងនានាក្នុងតំបន់អាស៊ាន នឹងបន្តបង្កើនចំណងមិត្តភាព និងផ្សារភ្ជាប់ខឿនសេដ្ឋកិច្ចរបស់ប្រទេសទាំងពីរឲ្យកាន់តែរឹងមាំ។ មិនត្រឹមតែនាំមកនូវឱកាសចូលទៅកាន់ទីផ្សាររវាងប្រទេសទាំងពីរ រាល់បណ្តាកិច្ចសហប្រតិបត្តិការ កិច្ចព្រមព្រៀងខាងលើនឹងបន្តបង្កើនឱកាសដល់អ្នកវិនិយោគវៀតណាម កម្ពុជា និងប្រទេសទី៣ ប្រើប្រាស់អោយអស់នូវសក្តានុពលរបស់ខ្លួន ដើម្បីបើកទូលាយនូវសកម្មភាពវិនិយោគពង្រីចផលិតផលអភិវឌ្ឍន៍ខ្សែសង្វាក់ផលិតកម្ម ដើម្បីពង្រីកវិសាលភាពនាំចេញឆ្ពោះទៅកាន់ទីផ្សារប្រទេសអាស៊ានដ៏ទៃទៀត និងទីផ្សារពិភពលោក។

## ▲ តួរលេខទំនិញវៀតណាមនាំចូលកម្ពុជា៣ខែ ដើមឆ្នាំ ២០២៥

(ប្រកាសថ្មីបំផុតរបស់នាយកដ្ឋានគយវៀតណាម ថ្ងៃទី ១០ ខែសីហា -២០២៥)

| មុខទំនិញ | ខែកក្កដា ២០២៥ | ធៀប មិថុនា -២០២៥(%) | ៧ខែដើម ឆ្នាំ ២០២៥ | (+/-)៧ខែ ឆ្នាំ ២០២៤(%) | ភាគរយ (%) |
|---|---|---|---|---|---|
| សរុប(USD) | 489,614,401 | 2.56 | 239,551,164 | 5.71 | ▲ 100 |
| មុខទំនិញ វាយនភ័ណ្ឌ | 86,504,019 | 23.29 | 33,162,132 | 7.52 | ▲ 16.46 |
| ដែកគ្រប់ប្រភេទ | 70,173,821 | -8.74 | 08,011,465 | 18.9 | ▲ 15.68 |
| វត្ថុធាតុដើមបន្ទាប់បន្សំដូចជា ស្បែកសត្វ អំបោះ .... | 35,722,798 | 32.01 | 232,449,084 | 11.4 | ▲ 7.18 |

| មុខទំនិញ | ខែកក្កដា ២០២៥ | ធៀប មិថុនា -២០២៥(%) | ៧ខែដើម ឆ្នាំ ២០២៥ | (+/-)៧ខែ ឆ្នាំ ២០២៤(%) | ភាគរយ (%) |
|---|---|---|---|---|---|
| ជីដាក់ដំណាំគ្រប់ប្រភេទ | 30,244,004 | -30.75 | 74,357,997 | 31.58 | ▲ 5.38 |
| ក្រដាសនិងផលិតផលពីក្រដាស | 18,115,491 | 6.15 | 09.562.474 | 17.35 | ▲ 3.38 |
| ផលិតផលពីដែកថែប | 14,394,866 | 7.72 | 96,767,328 | 31.73 | ▲ 2.99 |
| ចំណីសត្វនិងវត្ថុធាតុដើម | 17,069,177 | 3.79 | 95,870,500 | 44.23 | ▲ 2.96 |
| ប្រេងសាំងគ្រប់ប្រភេទ | 10,157,591 | 38.2 | 95,579,864 | -54.04 | ▲ 2.95 |
| ផលិតផលពីសារៈធាតុកំហាប់ | 14,484,715 | 11.51 | 93,975,085 | -29.66 | ▲ 2.9 |
| ម៉ាស៊ីន គ្រឿងបង្គុំ គ្រឿងបន្លាស់ និង ឧបករណ៍ផ្សេងៗ | 11,879,580 | -44.83 | 82,175,753 | 7.35 | ▲ 2.54 |
| លោហៈធម្មតា និង ផលិតផល | 10,664,791 | -5.55 | 78,819,010 | -17.22 | ▼ 2.43 |
| ផលិតផលគីមី | 11,641,481 | 11.68 | 70,372,918 | 5.71 | ▲ 2.17 |
| សូត្រសរសៃ អំបោះគ្រប់ប្រភេទ | 7,295,063 | 17.83 | 56,121,834 | 0.18 | ▲ 1.73 |
| ទំនិញផ្សេងទៀត | 55,632,388 | 416,36 | 325,273,048 | 202.10 | ▲ 10.22 |

# អំពីព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម

ព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម គឺជាព្រឹត្តិបត្របោះពុម្ពផ្សាយដោយនាយកដ្ឋានផែនការ ស្ថិតិ និងព័ត៌មានពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម។ ព្រឹត្តិបត្រនេះប្រមូលផ្តុំនូវមាតិកាសំខាន់ៗរួមមាន ស្ថិតិព័ត៌មានពាណិជ្ជកម្ម សន្ទស្សន៍ថ្លៃទំនិញចាំបាច់ ព័ត៌មានតម្លៃទំនិញសំខាន់ៗ លើទីផ្សារពិភពលោក និងអត្ថបទស្រាវជ្រាវ។

## សមាសភាពថ្នាក់ដឹកនាំ និងក្រុមការងារ

១- ឯកឧត្តម ប៉ែន សុវិជាតិ
២- លោកជំទាវ សេរី បូរាពេជ្រ
៣- លោក គន់ ឌីរ៉ង់
៤- លោកស្រី ឡុង លាបភា
៥- លោកស្រី ធន សាល័ក្ខណ៍
៦- លោកស្រី ថាច់ ម៉ារីយ៉ា
៧- លោក យឹម រ៉ុម
៨- លោក ស៊ិន សុខហេង
៩- លោក សេង សុគន្ធា (អ្នករចនា)

## សូមស្កេន QR Code ដើម្បីភ្ជាប់ទៅ បណ្តាញទំនាក់ទំនងសង្គមផ្លូវការរបស់ក្រសួងពាណិជ្ជកម្ម

Website
www.moc.gov.kh

Facebook
@moc.gov.kh

Telegram
@mocnewsfeed

YouTube
@mocgovkhcambodia

X Account
@MoCCambodia


ដីឡូត៍ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣ បេ) ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ ភ្នំពេញ ១២១០២
Lot 19-61 MOC Road (113B Road) Phum Teuk Thla , Sangkat Teuk Thla , Khan Sen Sok, Phnom Penh 12102
Email : dpsti.bulletin@moc.gov.kh